# កម្រងអត្ថបទសម្រាប់អ្នកជំនាញ
## តស៊ូមតិ

# ៦

# ការប្រែប្រួលសហគមន៍



កម្រងអត្ថបទសម្រាប់អ្នកជំនាញតស៊ូមតិនេះ គឺជាកម្រងឯកសារសិក្សា រៀបរៀងឡើងដោយកម្មវិធីតស៊ូមតិ និង គោលនយោបាយ



នៃអង្គការ Pact កម្ពុជា ដែលមានបរិយាយអំពីគោលការណ៍យុទ្ធសាស្ត្រ និង បច្ចេកទេស នៃយុទ្ធនាការតស៊ូមតិប្រកបដោយប្រសិទ្ធភាព។
កម្រងឯកសារនេះមានបោះពុម្ពជាកូនសៀវភៅចំនួនប្រាំមួយក្បាល គឺ :

**សៀវភៅ ទី ១** : ការគ្រប់គ្រងយុទ្ធនាការតស៊ូមតិ
**សៀវភៅ ទី ២** : ការកសាងទំនាក់ទំនងជាមួយរដ្ឋាភិបាល
**សៀវភៅ ទី ៣** : ការធ្វើការជាមួយប្រព័ន្ធផ្សព្វផ្សាយ
**សៀវភៅ ទី ៤** : ការកសាង និង ថែរក្សាក្រុមចម្រុះ
**សៀវភៅ ទី ៥** : ការតស៊ូមតិតាមរយៈសេវាកម្មច្បាប់
**សៀវភៅ ទី ៦** : ការប្រមែប្រមូលសហគមន៍

**កម្រងអត្ថបទសម្រាប់អ្នកជំនាញតស៊ូមតិ**
សៀវភៅទី ៦
ការប្រមែប្រមូលសហគមន៍


បោះពុម្ពលើកទី ១
ខែ តុលា ឆ្នាំ ២០០៦

ការបោះពុម្ពផ្សាយលេខ ១១-២០០៦

យើងលើកទឹកចិត្តឱ្យលោកអ្នកថតចម្លងផ្នែកណាមួយ ឬ ផ្នែកទាំងអស់នៃសៀវភៅនេះ និង ចែកចាយទៅអ្នកដទៃទៀត។


បោះពុម្ពដោយ រោងពុម្ពសាន់វេ ផ្ទះលេខ ៣១ ផ្លូវ ៣០២
ទូរស័ព្ទ: (៨៥៥-២៣) ៩៨៦ ៧២៥ / ០១២ ៨២៨ ១០០

# មាតិកា


ទំព័រ

២ សេចក្តីផ្តើម

៣ សិទ្ធិរបស់យើងនៅក្នុងសហគមន៍

៤ តើអ្វីជាសហគមន៍?

៥ ការប្រមែប្រមូលធនធានដើម្បីដោះស្រាយបញ្ហាសហគមន៍របស់អ្នក

៦ ហេតុអ្វីធ្វើការរួមគ្នា?

៧ បង្កើតក្រុមស្នូល

១២ អប់រំ និងពង្រឹងសហគមន៍របស់អ្នក

១៣ ស្វែងរកសម្ព័ន្ធមិត្ត

១៤ ធ្វើសកម្មភាពរួមគ្នា

១៥ សេចក្តីសន្និដ្ឋាន

១៧ ប្រភពឯកសារផ្សេងទៀត






**អ្នកនិពន្ធ**

អ្នកស្រី វិកធ័ររៀ អាយើ លោក ឈួន វុឌ្ឍី លោក កែម សម្បត្តិ

លោក សុខ សម្បត្តិ លោក ណែប ស៊ីនថៃ

**អ្នកកែសម្រួល**

លោក ឃីត ម៉ាកឡៅដ៍ អ្នកស្រី កែវ គៀង លោក យាប់ មេត្តា

កញ្ញា ជា សុភាព លោក ឡាំ សុជាតិ លោក នី កែវប៉ុញ្ញា

**អ្នកគាក់តែងរូបភាព**

លោក ផាន ភ័ព្វបារមី លោក ស៊ាន ស៊ីម៉ុនស៍

# សេចក្ដីផ្ដើម

ក្នុងគោលគំនិតជាសកល រដ្ឋាភិបាលត្រូវផ្ដល់សេវាប្រកបដោយប្រសិទ្ធភាព សាជីវកម្មផ្សេងៗត្រូវដំណើរការដោយមានការទទួលខុសត្រូវ និងប្រជាពលរដ្ឋប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកប្រកបដោយភាពត្រឹមត្រូវ និងការគោរព។ ទោះជាយ៉ាងណាក៏ដោយ យើងដឹងថាជារៀងរាល់ថ្ងៃសហគមន៍បានតស៊ូទាមទារឱ្យបានទទួលនូវសេចក្ដីត្រូវការមូលដ្ឋានការពារ ការកេងយកប្រយោជន៍អំពីធនធានធម្មជាតិ និងប្រឈមមុខចំពោះការរើសអើងនានា។ សៀវភៅនេះផ្ដល់នូវបច្ចេកទេស និងវិធីសាស្ត្រខ្លះៗ ដើម្បីជួយសកម្មជនក្នុងសហគមន៍ដែលជួបប្រទះនឹងបញ្ហាទាំងនេះ តាមរយៈការប្រមែប្រមូលប្រជាពលរដ្ឋឱ្យចូលរួមក្នុងយុទ្ធនាការតស៊ូមតិ។ តាមរយៈយុទ្ធសាស្ត្រយកសិទ្ធិមនុស្សជាមូលដ្ឋាន សកម្មជនទាំងឡាយអាចជួយគ្រួសារ មិត្តសំឡាញ់ និងអ្នករស់នៅជិតខាងរបស់គេ ដើម្បីរក្សាសិទ្ធិរបស់គេ និងទទួលបាននូវសេវាសង្គមយ៉ាងល្អប្រសើរ។



# សិទ្ធិរបស់យើងក្នុងសហគមន៍

ប្រជាពលរដ្ឋក្នុងសហគមន៍មានសិទ្ធិតស៊ូមតិ ដើម្បីអាចទទួលបានយ៉ាងល្អប្រសើរនូវដីធ្លី ឡូតិ៍នេសាទ ព្រៃឈើ សុខភាព ការអប់រំ និងសេវាកម្មផ្សេងៗ ។ សិទ្ធិទាំងនេះត្រូវបានការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

ពាក្យថា " យុទ្ធសាស្ត្រយកសិទ្ធិមនុស្សជាមូលដ្ឋាន" ជាញឹកញាប់គេប្រើដើម្បីរៀបរាប់អំពីយុទ្ធនាការដោះស្រាយបញ្ហាដែលមានមូលដ្ឋានលើតម្រូវការរបស់សហគមន៍មួយ ។ តើពាក្យនេះមានអត្ថន័យពិតប្រាកដយ៉ាងដូចម្តេច?

យុទ្ធសាស្ត្រយកសិទ្ធិមនុស្សជាមូលដ្ឋានមានន័យថា ពង្រឹងអំណាចប្រជាពលរដ្ឋឱ្យយល់ដឹង និងអនុវត្តសិទ្ធិរបស់ខ្លួន។ ក្នុងពេលជាមួយគ្នានេះដែរ គេរំពឹងថា រដ្ឋាភិបាលត្រូវបំពេញកាតព្វកិច្ចផ្សេងៗរបស់ខ្លួនដែរ ។ ជាទូទៅយើងបែងចែកប្រជាពលរដ្ឋជាពីរក្រុមធំគឺ ម្ចាស់សិទ្ធិ និងអ្នកមានកាតព្វកិច្ចគ្រប់គ្រង ។



**ម្ចាស់សិទ្ធិ :** ពាក្យនេះមានន័យថា បុគ្គល និងក្រុមទាំងឡាយដែលត្រូវបានគេផ្តល់សិទ្ធិជាពិសេសណាមួយ ។ ឧទាហរណ៍ : កុមារក្នុងប្រទេសកម្ពុជាមានសិទ្ធិ ដើម្បីទទួលការអប់រំដោយឥតបង់ថ្លៃ។ ប្រជាពលរដ្ឋកម្ពុជាទាំងអស់មានសិទ្ធិចៀសផុតពីការធ្វើទារុណកម្មពីភ្នាក់ងារនគរបាល ។ ពេលខ្លះសិទ្ធិរបស់ប្រជាពលរដ្ឋមិនត្រូវបានគេគោរព ហើយប្រជាពលរដ្ឋត្រូវតែតស៊ូ ដើម្បីទាមទារសិទ្ធិរបស់ពួកគេ ។

យុទ្ធសាស្ត្រយកសិទ្ធិមនុស្សជាមូលដ្ឋាន ជំរុញឱ្យមានការគោរព និងបំពេញនូវសិទ្ធិមនុស្ស និងតម្រូវឱ្យមានការចូលរួមយ៉ាងសកម្មដោយប្រជាពលរដ្ឋផងដែរ ដើម្បីរក្សាសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគេ និងធ្វើការតាមដានការអនុវត្តនានារបស់រដ្ឋាភិបាល ។





**អ្នកមានកាតព្វកិច្ចគ្រប់គ្រង :** គឺជាបុគ្គលទាំងឡាយដែលមានការទទួលខុសត្រូវ ដើម្បីការពារលើកស្ទួយ និងទទួលស្គាល់សិទ្ធិមនុស្សជាសំខាន់។ ពួកគេទទួលខុសត្រូវផងដែរ ក្នុងការការពារការរំលោភសិទ្ធិប្រជាពលរដ្ឋ។ ជាធម្មតាពួកគេជាជនដែលត្រូវបានបោះឆ្នោតជ្រើសរើស ឬមានតំណែងក្នុងជួររដ្ឋាភិបាល មានដូចជានគរបាល ចៅក្រម សមាជិកសភា អ្នកបម្រើការងារការិយាល័យ ព្រមទាំងនាយករដ្ឋមន្ត្រីផង ។

រដ្ឋាភិបាលមានភារកិច្ច បំពេញកាតព្វកិច្ចរបស់ខ្លួនជូនប្រជាពលរដ្ឋ។ ការទទួលខុសត្រូវរបស់រដ្ឋាភិបាលមាន ការផ្តល់សេវាអប់រំ ការថែរក្សាសុខភាព និងការពារសិទ្ធិមនុស្ស គឺមិនត្រូវសំដៅតែបុគ្គលណាមួយដែលមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹងមន្ត្រីរាជការឡើយ ។ ប្រជាពលរដ្ឋគួរតែទទួលបាននូវសេវាជាមូលដ្ឋាននានា ពីព្រោះវាជាសិទ្ធិ មិនមែនជាអំណោយទេ ។

# តើសហគមន៍ជាអ្វី?

សហគមន៍ គឺជាមនុស្សមួយក្រុមដែលរស់នៅក្នុងតំបន់ដូចគ្នា (ឧទាហរណ៍ៈ ភូមិ ឃុំ ក្រុង បុរី ឬ តំបន់ផ្សេងៗនៃទីក្រុង) រួមប្រាស្រ័យទាក់ទងគ្នានៅក្នុងសង្គម និងមានចំណាប់អារម្មណ៍រួមគ្នាមួយ ។



សហគមន៍ទាំងអស់គួរតែជួយកំណត់រកមើល និងប្រមែប្រមូលធនធានផ្ទាល់ខ្លួនប្រកបដោយប្រសិទ្ធភាព។ វាមានសារៈសំខាន់ណាស់នៅពេលដែលបញ្ហាមួយត្រូវបានកំណត់ ហើយសមាជិកសហគមន៍ទាំងអស់ត្រូវអញ្ជើញឱ្យចូលរួមពាក់ព័ន្ធក្នុងការពិភាក្សា ការរៀនសូត្រ ការវិភាគ ការចែករំលែកគំនិត និងធ្វើសកម្មភាពរួមគ្នា ដើម្បីដោះស្រាយបញ្ហានោះ ក្នុងគោលបំណង កសាងសហគមន៍មួយប្រកបដោយភាពឯករាជ្យ ម្ចាស់ការ ស្វ័យគ្រប់គ្រង និងកែលំអជីវភាពរស់នៅរបស់ពួកគេ។

# ការប្រមែប្រមូលធនធាន
# ដើម្បីដោះស្រាយបញ្ហាសហគមន៍របស់អ្នក

សៀវភៅនេះចែកដំណើរការនៃការចលនា និងប្រមែប្រមូលធនធានរបស់សហគមន៍របស់អ្នកជា ៥ ជំហានសំខាន់ៗគឺ :



# ១ ហេតុអ្វីធ្វើការរួមគ្នា?



តាមរយៈការធ្វើការរួមគ្នា ដើម្បីដោះស្រាយបញ្ហាពួកគេផ្ទាល់ សហគមន៏អាចៈ

- កសាងការឯកភាព និងសាមគ្គីភាពក្នុងចំណោមសមាជិកពួកគេ
- លើកស្ទួយការសម្រេចចិត្តរួម ដែលអាចដោះស្រាយទំនាស់ ដោយសន្តិវិធី និងអាចការពារកុំឱ្យមានទំនាស់កើតឡើង។
- ដាក់សម្ពាធដល់អ្នកមានកាតព្វកិច្ចគ្រប់គ្រង ឬ អ្នកធ្វើសេចក្តីសម្រេច លើការផ្តល់សេវានានា
- ផ្លាស់ប្តូរគោលនយោបាយ ឬ ច្បាប់ដែលប៉ះពាល់ចំពោះសហគមន៏

ដើម្បីសម្រេចបាននូវក្តីរំពឹងទាំងនេះ សហគមន៏ ឬក្រុមស្នូលចាំបាច់ត្រូវធ្វើការរួមគ្នាយ៉ាងជិតស្និទ្ធ និងឃ្លាំមើលជាប្រចាំ ដើម្បីបង្កើតទំនាក់ទំនងជាមួយសម្ព័ន្ធមិត្តដែលមានសក្តានុពល និងមានស្រាប់ និងបង្កើនការគាំទ្រពីពួកគេ។

កត្តាប្រឈមមុខចំពោះសហគមន៏ដែលប្រមែប្រមូលធនធានដើម្បីដោះស្រាយបញ្ហាពួកគេះ
- ប្រជាពលរដ្ឋអាចប្រឈមមុខនឹងគ្រោះភ័យខាងជីវភាព ឬសេដ្ឋកិច្ច និងរាងកាយ នៅពេលដែលពួកគេទាមទារសិទ្ធិរបស់ពួកគេ
- វាអាចជាការលំបាកដើម្បីបញ្ចុះបញ្ចូលប្រជាពលរដ្ឋឱ្យបានគ្រប់គ្រាន់ ដើម្បីចូលរួមជាមួយយើង
- ការពង្រឹងប្រជាពលរដ្ឋ និងធនធាន ដើម្បីតទល់នឹងបញ្ហា អាចចំណាយពេលវេលាច្រើន
- ប្រជាពលរដ្ឋមានទស្សនៈនិងកម្រិតនៃការតាំងចិត្តផ្សេងៗគ្នាដែលអាចនាំឱ្យមានការមិន ចុះសម្រុងគ្នា។
- អាចត្រូវការពេលយូរដើម្បីយកជ័យជម្នះលើ ប្រព័ន្ធការិយាធិបតេយ្យនៅក្នុងជួររដ្ឋាភិបាល។

**ដើម្បីលើកឡើងអំពីតម្រូវការ បញ្ហា និង កត្តាប្រឈមរបស់សហគមន៏ អ្នកត្រូវតែបង្កើត ក្រុមស្នូល ដោយមានសមាជិកដែលមានការប្តេជ្ញាចិត្ត ដើម្បីដឹកនាំ និងសម្របសម្រួលការពិភាក្សា ការចែករំលែក ការវិភាគ និង ការធ្វើសកម្មភាពរួមគ្នា។**



## ២ បង្កើតក្រុមស្នូល

ពេលចាប់ផ្ដើមដំបូងប្រជាពលរដ្ឋក្នុងសហគមន៍របស់អ្នកមិនអាចមានអារម្មណ៍ពីភាពចាំបាច់ដូចដែលអ្នកគិតអំពីការដោះស្រាយបញ្ហាឡើយ។ ជាច្រើនលើកពួកគេមិនទាំងជឿថា នោះជាបញ្ហាផង។ ការបញ្ចុះបញ្ចូលប្រជាពលរដ្ឋឱ្យចូលរួមគឺជាកិច្ចការលំបាកមួយ ប៉ុន្តែបញ្ហាសហគមន៍របស់អ្នកត្រូវបង្កើតឡើងដោយបុគ្គលច្រើននាក់ ដូច្នេះអ្នកនឹងត្រូវការមនុស្សជាច្រើនធ្វើការរួមគ្នា ដើម្បីដោះស្រាយបញ្ហានោះ។



ដំបូងអ្នកនឹងចង់រៀបចំក្រុមស្នូលតូចមួយរបស់ប្រជាពលរដ្ឋ ដើម្បីធ្វើការរួមគ្នា។ ក្រុមស្នូលនេះនឹងទទួលខុសត្រូវក្នុងការប្រមូលទិន្នន័យអំពីបញ្ហា និងបង្កើតនូវយុទ្ធសាស្ត្ររយៈពេលវែងមួយ។ ការរកមេដឹកនាំ និងសមាជិកប្រកបដោយប្រសិទ្ធភាពគឺជាជំហានសំខាន់មួយ ក្នុងការដោះស្រាយបញ្ហាសហគមន៍របស់អ្នក។ អ្នកដឹកនាំលេចចេញពីប្រភពជាច្រើន ហើយមិនតែងតែមានតួនាទីផ្លូវការក្នុងសហគមន៍ទេ។ មេដឹកនាំល្អអាចសម្ដែងនូវអារម្មណ៍យ៉ាងជ្រាលជ្រៅ និងទាក់ទាញឱ្យមានការចាប់អារម្មណ៍ពីអ្នកដទៃ ដើម្បីសឱ្យឃើញពីបញ្ហាដែលកើតមានឡើង និងកិច្ចការចាំបាច់ខ្លះដែលត្រូវឆ្លើយតបចំពោះបញ្ហានោះ។ មេដឹកនាំនេះនឹងបង្កើតនូវថាមវន្តចាំបាច់មួយចំនួន ដើម្បីអប់រំ និងប្រមែប្រមូលសហគមន៍។ មេដឹកនាំនេះអាចជារូបអ្នកតែម្ដង !

### លក្ខណៈសម្បត្តិមេដឹកនាំ និងអ្នកដើរតាម

| មេដឹកនាំល្អ | អ្នកដើរតាមល្អ |
| --- | --- |
| - ជាវាគ្មិនមានថ្វីមាត់ និងពូកែបញ្ចុះបញ្ចូល<br>- លើកទឹកចិត្តអ្នកដទៃ ប្រកបដោយក្ដីគោរព<br>- ហ៊ានប្រថុយប្រថាន<br>- ផ្ទេរការងារសំខាន់ៗទៅអ្នកដើរតាម<br>- ជួយដោះស្រាយទំនាស់នានា<br>- ជំរុញឱ្យមានការដោះស្រាយបញ្ហា ប្រកបដោយការច្នៃប្រឌិត<br>- ចែករំលែកព័ត៌មាន<br>- ទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន<br>- ធ្វើទំនាក់ទំនង និងបំផុសស្មារតីសមាជិក<br>- មានគោលការណ៍ និងសម្បជញ្ញៈផ្ទាល់ខ្លួន<br>- មានជំនឿថាអំណាចត្រូវបានប្រើប្រាស់យ៉ាងប្រសើរបំផុត ប្រសិនបើមានការចែករំលែក | - ស្វែងរកវិធីនានា ដើម្បីសម្រេចឱ្យបាននូវគោលដៅដែលស្របគ្នាជាមួយទស្សនវិស័យរបស់មេដឹកនាំ<br>- ប្រើការច្នៃប្រឌិត ចំណេះដឹង និងការយល់ដឹងស៊ីជម្រៅ ដើម្បីចាប់យកគំនិតផ្ដួចផ្ដើម និងឆ្លើយតបបានឆាប់រហ័ស។<br>- មានភាពស្មោះត្រង់ចំពោះសហគមន៍ និងមានឆន្ទៈអនុវត្តតាមជំនឿរបស់ពួកគេ<br>- ស្វែងយល់ពីសហគមន៍ និងការចូលរួមរបស់ពួកគេ<br>- យល់ដឹងគ្រប់ជ្រុងជ្រោយ និងបត់បែនសមល្មម ដើម្បីសម្របខ្លួនតាមបរិយាកាសដែលកំពុងផ្លាស់ប្ដូរ។<br>- ទទួលខុសត្រូវចំពោះសកម្មភាព និងគំនិតផ្ទាល់ខ្លួនរបស់ពួកគេ។ |



# ជ្រើសរើសសមាជិកក្រុមស្នូល

តាមពិតវាមានសារៈសំខាន់ណាស់ ដើម្បីឱ្យប្រជាពលរដ្ឋដែលមានសមត្ថភាព និងជំនាញផ្សេងៗគ្នា ចូលរួមឱ្យបានច្រើនក្នុងកិច្ចប្រឹងប្រែងរបស់អ្នក។ ប៉ុន្តែក្រុមស្នូលត្រូវការប្រជាពលរដ្ឋប្រភេទដោយឡែកខ្លះ។ ដើម្បីឱ្យឱកាសជោគជ័យរបស់អ្នកទទួលបានជាអតិបរមា អ្នកគួរតែប្រឹងប្រែងកសាងនូវទំនោរចិត្តឱ្យដើរតាមជនដែលគេកំពុងកោតសរសើរ។ ក្រុមស្នូលរបស់អ្នកគួរតែមានប្រជាពលរដ្ឋមកពីសហគមន៍ដែលដើរតួជា :

## ខួរក្បាល

ប្រជាពលរដ្ឋផ្សេងៗអាចស្នើសុំដំបូន្មានដែលអាចជឿជាក់បាន

## បេះដូង

មានការផ្សារភ្ជាប់ទៅជាមួយប្រជាពលរដ្ឋជាច្រើន និងសប្បាយចិត្តក្នុងការបង្កើតសម្ព័ន្ធភាពក្នុងចំណោមប្រជាពលរដ្ឋ

## មាត់

និយាយបញ្ចុះបញ្ចូល និងធ្វើឱ្យជនដទៃទៀតផ្លាស់ប្តូរមតិយោបល់ និងទម្លាប់ពួកគេ

ក្រោយពីកំណត់រកមើលជនប្រភេទទាំងបីនេះរួច ចូរពិភាក្សាជាមួយពួកគេ។ ដំបូងពួកគេមិនអាចយល់បានអំពីរឿងរ៉ាវ ឬ បញ្ហាទេ។ វាជាការងាររបស់អ្នកក្នុងនាមជាសកម្មជនរបស់សហគមន៍ ដើម្បីពន្យល់អំពីសារៈសំខាន់ ក្នុងការធ្វើសកម្មភាពឥឡូវនេះ និងផ្តល់នូវហេតុផលល្អៗ ថាហេតុអ្វីពួកគេគួរតែចូលរួមជាមួយបុព្វហេតុរបស់អ្នក។



ពេល ណាក៏ដោយដែលប្រជាពលរដ្ឋធ្វើការរួមគ្នា វាអាចនឹងកើតមានការរាំងស្ទះ ឬទំនាស់ខ្លះៗមិនខាន។ កម្រិតផ្សេងៗគ្នានៃជំនាញ អាចបណ្តាលឱ្យប្រជាពលរដ្ឋមានអារម្មណ៍ច្រណែននឹងសមត្ថភាពអ្នកដទៃ។ ដោយសារកម្រិតផ្សេងៗគ្នានៃការប្តេជ្ញាចិត្ត អាចបណ្តាលឱ្យប្រជាពលរដ្ឋមានអារម្មណ៍អន់ចិត្ត ប្រសិនបើពួកគេជឿថា ប្រជាពលរដ្ឋខ្លះខ្ជិលច្រអូស។ ត្រូវធានាឱ្យបានថាជនគ្រប់រូបមានអារម្មណ៍ថា វិភាគទានរបស់ពួកគេ ទោះបីជាតូច ឬធំក្តី គឺវាមានសារៈសំខាន់។ ធ្វើការប្តូរវេនតួនាទីជាអ្នកដឹកនាំដោយបង្កលក្ខណៈឱ្យប្រជាពលរដ្ឋផ្សេងទៀតដើរតួជាអធិបតីអង្គប្រជុំ ឬក៏ជាអ្នករៀបចំទិវាអ្វីមួយ។ ត្រូវចៀសវាងកុំឱ្យជនម្នាក់ ឬ ពីរនាក់និយាយច្រើនតែឯងក្នុងការសន្ទនា ដាក់ពេលវេលាកំណត់ឱ្យប្រជាពលរដ្ឋអាចនិយាយបាន។ ត្រូវទទួលស្គាល់ និងលើកសរសើរដល់សំណូមពរ និងគំនិតរបស់ប្រជាពលរដ្ឋ ទោះបីជាពួកគេមានគំនិតផ្ទុយពីគំនិតអ្នកក៏ដោយ។ ប្រើវិធីសាស្ត្របែបប្រជាធិបតេយ្យ

# កំណត់បញ្ហា

ក្រុមស្នូលរបស់អ្នក ពេលនេះគួរតែធ្វើការស្រាវជ្រាវ និងប្រមូលព័ត៌មានស្ដីពីរបៀបដែលបញ្ហានេះវាជះឥទ្ធិពលដល់សហគមន៍របស់អ្នក។ ការយល់ដឹងពីបញ្ហា ជួយឱ្យអ្នកបញ្ចុះបញ្ចូលសមាជិកផ្សេងៗទៀតរបស់សហគមន៍ចូលរួមជាមួយបុព្វហេតុរបស់អ្នក និងផ្ដល់ភស្តុតាងដល់អ្នកដើម្បីអាចបង្ហាញដល់អ្នកធ្វើសេចក្ដីសម្រេច ឬ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបាន។ ចូរចងចាំថា ព័ត៌មានដែលល្អត្រឹមត្រូវជាការប្រសើរជាងព័ត៌មានខ្សឹបខ្សៀវ។ មនុស្សដែលនៅក្នុងមុខតំណែងពោរពេញដោយអំណាច មិនអាចធ្វើមិនដឹងមិនឮដោយងាយៗចំពោះភស្តុតាងដែលល្អត្រឹមត្រូវនោះឡើយ។

**ការស្រាវជ្រាវជាគោល អាចបញ្ចូលសកម្មភាពទាំងឡាយដូចជា ការជួបប្រជុំជាបុគ្គល និងជាក្រុម ហើយនិងការស្ទាបស្ទង់មតិ។**

**ឧទាហរណ៍:**

**បញ្ហា:** គ្រួសារភាគច្រើននៅក្នុង " ភូមិស្វាយ "របស់យើង គឺជាកសិករក្រីក្រ។ រដ្ឋាភិបាលបានផ្ដល់ដីសម្បទាននៅភូមិដែលជាប់នឹងភូមិយើងទៅឱ្យក្រុមហ៊ុនបរទេស។ ដោយគ្មានការពិគ្រោះយោបល់ ក្រុមហ៊ុនបានស្ថាបនាផ្លូវថ្នល់ឆ្លងកាត់ និងបានធ្វើរបងជុំវិញតំបន់នោះនៅជិតភូមិយើង។ អ្នកចាស់ទុំម្នាក់នៅក្នុងភូមិយើង មានឯកសារថតចម្លងអំពីប្លង់របស់ក្រុមហ៊ុន ដែលបានបង្ហាញថា គេនឹងរឹបអូសយកដីពីភូមិយើងនៅពេលបន្ទាប់នេះ។

**ជំហានទី១:** បង្កើតផែនទីបញ្ហារបស់សហគមន៍ បង្ហាញពីទំនាស់ដីធ្លីដែលអាចកើតឡើងប៉ះពាល់ដល់ប្រជាពលរដ្ឋ។ ដើរទៅតាមផ្ទះនីមួយៗហើយសួរនាំពួកគេ:

- តើក្រុមគ្រួសារលោកអ្នក មានដីទំហំប៉ុន្មានហិកតា? បានដាំដំណាំហើយឬនៅ?
- តើនឹងមានផលប៉ះពាល់យ៉ាងណា បើគ្រួសារលោកអ្នកបាត់បង់ដី?
- តើវានឹងមានការផ្លាស់ប្ដូរអ្វីខ្លះចំពោះគ្រួសារ បើសិនជាលោកអ្នកបាត់បង់ចំណូល? តើលោកអ្នក នៅតែបរិភោគបាយតាមបរិមាណដដែលដូចអ្វីដែលអ្នកធ្លាប់បរិភោគឬទេ? តើកូនៗរបស់លោកអ្នក នឹងនៅតែបានទៅរៀនជាបន្តដែរឬទេ?
- តើលោកអ្នកគិតថា អាចទៅរកនរណាម្នាក់ឱ្យជួយដោះស្រាយបញ្ហា? ប្រសិនបើគ្មាន ហេតុអ្វី?



ត្រូវប្រាកដថា អ្នកសម្ភាសន៍ត្រូវដឹងពីអារម្មណ៍អ្នកឆ្លើយ និងចេះគួរសមនៅពេលដែលធ្វើការសម្ភាសន៍។ មានមនុស្សជាច្រើនតែងខ្មាសអៀន ឬខ្វល់ខ្វាយចិត្តអំពីអសមត្ថភាពរបស់គេ ក្នុងការចែកចាយបទពិសោធន៍ ការនិយាយជាសាធារណៈ ឬការសន្ទនាជាមួយអ្នក។ ប្រជាពលរដ្ឋប្រហែលជាមិនត្រូវបានគេលើកទឹកចិត្តឱ្យពិភាក្សាគ្នាអំពីបញ្ហាដីធ្លីជាចំហទេ ពីព្រោះពួកគេភ័យខ្លាចមានការបៀតបៀនដោយក្រុមហ៊ុន ឬក៏ជឿជាក់ថា អាជ្ញាធរមូលដ្ឋាននឹងប្រើឥរិយាបថមិនល្អ( ទ្រគោះ) ឬពុករលួយ។ ហើយក៏ត្រូវប្រាកដផងដែរថា អ្នកសម្ភាសន៍របស់អ្នកត្រូវមានការយល់ដឹងច្បាស់លាស់អំពីស្ថានភាពទីនោះទាំងស្រុង។

បន្ទាប់ពីប្រមូលព័ត៌មាន អ្នកត្រូវធ្វើផែនទីបញ្ហា

## ផែនទីបញ្ហារបស់សហគមន៍ភូមិស្វាយ



លោកសារិន ជាជនពិការជើងទាំងពីរ។ គាត់មានកូន៥នាក់។ គាត់មានដីតែកន្លះហិកតា សម្រាប់ដាំបន្លែ និងស្រូវតាមរដូវ។ ប្រសិនបើដីកន្លែងណាមួយរបស់គាត់ ត្រូវបានគេរឹបអូសយកនោះ ក្រុមគ្រួសារគាត់នឹងត្រូវបង្ខំឱ្យចាកចេញពីដី និងផ្ទះសម្បែង។

ក្រុមគ្រួសាររបស់លោកសុខ មានដីមួយហិកតាសម្រាប់ដាំដើមឈើហូបផ្លែ និងដាំបន្លែតាមរដូវ ។គាត់មានកូន៦នាក់។ ចំណូលជាចម្បងរបស់គាត់បានមកពីការដាំដុះលើដីនេះ។ ដីរបស់គាត់ទាំងអស់អាចនឹងត្រូវបានរឹបអូសយកដោយក្រុមហ៊ុន។

អ្នកស្រី យឿន មានកូន៤នាក់ និងម្ដាយចាស់ជរាម្នាក់។ គាត់មានដីតែ កន្លះ ហិកតាសម្រាប់ស្ទូងស្រូវ ហើយអ្នកស្រីបានព្យាយាមស្ទូងស្រូវពីរដងក្នុងមួយឆ្នាំ។ ទំហំពាក់កណ្ដាលនៃដីរបស់គាត់ អាចនឹងត្រូវបានរឹបអូសយកដោយក្រុមហ៊ុន។ ប្រសិនបើដីរបស់គាត់ត្រូវបានគេរឹបអូសយកនោះ គាត់នឹងមិនអាចទ្រទ្រង់ដល់កូនប្រុសពៅរបស់គាត់ឱ្យទៅរៀនបានទៀតទេ។

បន្ទាប់ពីអ្នកបានប្រមូលទិន្នន័យ អ្នកគួរលើកជាសំណួរនៅក្នុងក្រុមស្នូលៈ តើអ្វីទៅជាផលប៉ះពាល់ខ្លាំង នៅក្នុងសហគមន៍របស់អ្នក? តើមានប្រជាពលរដ្ឋប៉ុន្មាននាក់នឹងក្លាយទៅជាអ្នកអត់ឃ្លាន ប្រសិនបើដីរបស់ពួកគេត្រូវបានរឹបអូសយក? តើមានកុមារប៉ុន្មាននាក់ដែលមិនអាចទៅរៀនបន្តទៀត? តើមានគ្រួសារប៉ុន្មាននឹងត្រូវចាកចេញ? តើមានប្រជាពលរដ្ឋប៉ុន្មានមានប័ណ្ណកម្មសិទ្ធិលើដីធ្លីរបស់គេ? តើមានប្រជាពលរដ្ឋប៉ុន្មាននាក់កំពុងរស់នៅខុសច្បាប់?

នៅក្នុងឧទាហរណ៍នេះក្រុមស្នូលបានសម្រេចថា បញ្ហាពិតប្រាកដនោះជាការខ្វះខាតនូវការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋអំពីដីសម្បទាននិងការខ្វះខាតព័ត៌មានអំពីការទទួលប័ណ្ណកម្មសិទ្ធិដីធ្លីរបស់គេ។ ក្រុមស្នូលបានសម្រេចចិត្តថា ពួកគេត្រូវតែផ្ដោតការយកចិត្តទុកដាក់ ទៅលើការខិតខំប្រឹងប្រែងរបស់គេទៅលើតម្រូវការសិទ្ធិរស់រានមានជីវិត និងភាពជាម្ចាស់កាន់កាប់ដីនៅកន្លែងដែលពួកគេរស់នៅជាច្រើនឆ្នាំមកហើយនោះ។

# ការស្រាវជ្រាវបញ្ហារបស់លោកអ្នក

នៅពេលដែលអ្នកស្រាវជ្រាវពីបញ្ហារបស់សហគមន៍ អ្នកត្រូវស្វែងយល់ផងដែរថា តើរាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងលើដំណោះស្រាយឬទេ? សាកសួរសមាជិកក្រុមប្រឹក្សាឃុំ មន្ត្រីមូលដ្ឋាន ឬខុទ្ទកាល័យនាយករដ្ឋមន្ត្រី ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម។ ប្រហែលជាវាមានរួចមកហើយនូវការគ្រប់គ្រងថ្នាក់ជាតិ ឬច្បាប់ដែលអាចនឹងជួយយើងបាន។ អ្វីដែលជាដំណោះស្រាយងាយស្រួលបំផុតនោះ គឺប្រតិបត្តិតាមអ្វី ដែលមានជាធរមានហើយ។

លើសពីនេះទៅទៀត អ្នកគួរដឹងថា រាជរដ្ឋាភិបាលកម្ពុជាបានយល់ព្រមរួចហើយដើម្បីគោរពសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ជាអាទិ៍សិទ្ធិពលរដ្ឋ នយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌។ (ព័ត៌មានលម្អិតអំពីការស្វែងរកឯកសារសិទ្ធិមនុស្សអន្តរជាតិមាននៅផ្នែកខាងក្រោយនៃសៀវភៅនេះ)។

ជួនកាលអ្នកប្រហែលជាអាចដឹងថា ខ្លួនមានព័ត៌មាន ឬចំណេះដឹងច្រើនជាងមន្ត្រីរដ្ឋាភិបាលដែលទទួលខុសត្រូវមាន។ មានមនុស្សជាច្រើនត្រូវបានបោះឆ្នោតជ្រើសរើស ឬតែងតាំងនៅក្នុងមុខតំណែងដោយសារភក្ដីភាពរបស់គេចំពោះគណបក្សនយោបាយជាជាងជំនាញវិជ្ជាជីវៈរបស់គេផ្ទាល់លើបញ្ហាអ្វីមួយ។ បែបនេះវាជាស្ថានភាពធម្មតាមួយ នៅពាសពេញពិភពលោក។ ទោះជាយ៉ាងណាក៏ដោយ ក៏មិនអាចអត់ទោសឱ្យចំពោះការមិនបំពេញតួនាទីរបស់ខ្លួនឡើយ។ ចូរចងចាំថា អ្នកជាម្ចាស់សិទ្ធិ (ប្រជាពលរដ្ឋ)។ ការយល់ដឹងអំពីសិទ្ធិ និងទាមទារសិទ្ធិជាផ្នែកនៃការទទួលខុសត្រូវរបស់អ្នក។ ប្រសិនបើអ្នកមានកាតព្វកិច្ចគ្រប់គ្រង (មន្ត្រីរាជការ) ខកខានមិនបានគោរពសិទ្ធិប្រជាពលរដ្ឋ ប្រជាពលរដ្ឋមានអំណាចពីរយ៉ាងគឺ សំឡេង និងសន្លឹកឆ្នោត។

# បង្កើតយុទ្ធសាស្ត្រ

នៅពេលណាដែលអ្នកបានវិភាគការស្រាវជ្រាវរបស់អ្នកហើយ ក្រុមស្នូលរបស់អ្នកត្រូវបង្កើតយុទ្ធសាស្ត្រមួយដែលត្រូវកំណត់ច្បាស់លាស់នូវ ៖
- កំណត់បញ្ហា និង ឥរិយាបថដែលត្រូវផ្លាស់ប្តូរ
- តើសកម្មភាពអ្វីដែលអ្នកនឹងត្រូវធ្វើ និង តើធនធានអ្វីដែលអ្នកនឹងត្រូវការ?
- តើអ្នកណាដែលយើងត្រូវទំនាក់ទំនងនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ?
- តើមន្ត្រីសាធារណៈ និង សម្ព័ន្ធមិត្តណាដែលយើងត្រូវជួប?

សូមកុំភ្លេចកំណត់អ្នកទទួលខុសត្រូវលើកិច្ចការនីមួយៗឱ្យបានច្បាស់លាស់ និងកំណត់ពេលវេលាសម្រាប់សកម្មភាពដែលត្រូវបំពេញ។

## យុទ្ធសាស្ត្រដើម្បីប្រមែប្រមូលសហគមន៍ដើម្បីការពារជីវិតរបស់យើង

| តើយើងនឹងធ្វើអ្វី? | តើយើងនឹងធ្វើនៅពេលណា? | តើយើងត្រូវការអ្វីខ្លះ? | តើអ្នកណាទទួលខុសត្រូវ? |
|---|---|---|---|
| រៀបចំប្រជុំជាមួយក្រុមប្រឹក្សាឃុំ | ភ្លាមៗ | - ផ្ញើលិខិតទៅកាន់ក្រុមប្រឹក្សាឃុំ ដើម្បីស្នើសុំឱ្យមានការប្រជុំ<br>- រៀបចំរបៀបវារៈ និងសម្រេចអំពីអ្នកចូលរួម<br>- នាំយកនូវច្បាប់ចម្លងផែនទីបញ្ហារបស់សហគមន៍ទៅកាន់អង្គប្រជុំ។ សុំក្រុមប្រឹក្សាឃុំឱ្យជួយរៀបចំកិច្ចប្រជុំមួយជាមួយក្រុមហ៊ុន។ | **សុជាតិ** |
| ចូលរួមក្នុងកម្មវិធីផ្សាយបន្តផ្ទាល់ ដើម្បីពិភាក្សាអំពីរបៀបចុះបញ្ជីដីរបស់អ្នកដោយការប្រើប្រាស់ច្បាប់ភូមិបាល | ១សប្តាហ៍ទៀត | - ទំនាក់ទំនងស្ថានីយ៍វិទ្យុ<br>- ជ្រើសរើសអ្នកនាំពាក្យដែលនឹងនិយាយក្នុងកម្មវិធីវិទ្យុ<br>- រៀបចំសុន្ទរកថា និង សាកល្បងឆ្លើយសំណួរ ផ្សេងៗ<br>- រៀបចំឱ្យមានអ្នកស្ម័គ្រចិត្តជាស្រេច ដើម្បីសួរសំណួរក្នុងកម្មវិធីវិទ្យុ | **សុភាព** |
| ការប្រកួតប្រជែងសិល្បៈរបស់សិស្សលើប្រធានបទ ដីយើង ជីវិតយើង សម្រាប់សហគមន៍យើង! | ចាប់ផ្តើមក្នុងពីរសប្តាហ៍ទៀត | - រៀបចំឱ្យមានអ្នកស្ម័គ្រចិត្តដើម្បីទៅពិភាក្សា និង សុំការអនុញ្ញាត និងប្រកាសដល់សិស្ស<br>- បិទលទ្ធផលប្រកួតប្រជែងសិល្បៈនៅសាលាឃុំ | **មេត្តា** |
| រៀបចំទិវាចុះបញ្ជីកាន់កាប់ដីធ្លី ដើម្បីធានាថាអ្នកភូមិគ្រប់គ្នាបានចុះបញ្ជីកាន់កាប់ដីធ្លីរបស់ពួកគេ ដោយស្របច្បាប់ | ក្នុងរយៈពេលមួយខែ | - អ្នកស្ម័គ្រចិត្តដើរពីផ្ទះមួយទៅផ្ទះមួយ នឹងជំរុញឱ្យអ្នកភូមិទាំងឡាយចូលរួម និង ជួយអ្នកភូមិឱ្យយល់អំពីតម្រូវការផ្សេងៗ សម្រាប់ការចុះបញ្ជី<br>- ទំនាក់ទំនងការិយាល័យចុះបញ្ជីដីធ្លីដែលពាក់ព័ន្ធ ដើម្បីបញ្ជូនអ្នកតំណាងមកចូលរួម<br>- សុំការអនុញ្ញាតពីអាជ្ញាធរដែនដី ដើម្បីរៀបចំព្រឹត្តិការណ៍<br>- តែងតាំងអ្នកទទួលខុសត្រូវលើសន្តិសុខ និងគ្រឿងភស្តុភារ<br>- អញ្ជើញប្រព័ន្ធផ្សព្វផ្សាយចូលរួមក្នុងព្រឹត្តិការណ៍ និងជ្រើសរើសតំណាងម្នាក់ ឬពីរនាក់ ដើម្បីនិយាយជាមួយប្រព័ន្ធផ្សព្វផ្សាយ<br>- ដាក់ជូននូវឯកសារចុះបញ្ជីដីធ្លីទៅការិយាល័យភូមិបាល | **ស៊ីនថៃ** |

# ៣ អប់រំ និង ពង្រឹងសហគមន៍របស់អ្នក

មនុស្សជាច្រើនតែងតែចៀសវាងការព្យាយាមរកដំណោះស្រាយ នៅពេលប្រឈមមុខជាមួយបញ្ហាលំបាក។ នេះហាក់បីដូចជាចម្លែក ប៉ុន្តែវាជាការឆ្លើយតបបែបធម្មជាតិរបស់មនុស្ស ជាពិសេស ប្រសិនបើអ្នកមិនអាចរកឃើញវិធីដោះស្រាយស្ថានភាពឱ្យល្អប្រសើរ។ មិនតែប៉ុណ្ណោះអ្នកអាចគិតថា ប្រសិនបើអ្នកព្យាយាម កែប្រែស្ថានភាពអ្នក ឬ គ្រួសាររបស់អ្នក អាចនឹងត្រូវទទួលគ្រោះថ្នាក់ ឬទទួលការគំរាមកំហែង។

ការជួយប្រជាពលរដ្ឋឱ្យទទួលស្គាល់ និងយល់ដឹងនូវមូលហេតុដែលនាំឱ្យយើងចាត់វិធានការហៅថា "ការបណ្តុះមនសិការ "។ សកម្មជនសហគមន៍អាចធ្វើការបណ្តុះមនសិការប្រជាពលរដ្ឋតាមរយៈ

- ជំរុញឱ្យមានការសន្ទនាជាក្រុមក្នុងចំណោមប្រជាពលរដ្ឋដែលមានបញ្ហាដូចគ្នា
- និយាយជាមួយប្រជាពលរដ្ឋថា តើជីវិតរបស់ពួកគេនឹងមានភាពប្រសើរយ៉ាងណា ប្រសិនបើពួកគេ ធ្វើការដោះស្រាយស្ថានការណ៍
- ពិភាក្សា និងស្វែងរកផ្លូវដើម្បីដោះស្រាយបញ្ហាសហគមន៍របស់ពួកគេ។

**ឧទាហរណ៍ : រៀបចំការប្រជុំសហគមន៍**

ក្រុមស្នូលជឿជាក់ថា បើមិនមានសកម្មភាពពីអ្នកភូមិទេ ក្រុមហ៊ុននឹងរឹបអូសយកដីអ្នកភូមិស្វាយជាមិនខាន។ ដើម្បីពង្រឹងប្រជាពលរដ្ឋ ក្រុមស្នូលបានប្រមូលប្រជាពលរដ្ឋ ដើម្បីចូលរួមប្រជុំនៅពេលរសៀលមួយ។ ក្រុមស្នូលចង់ឱ្យពលរដ្ឋផ្តល់នូវរឿងរ៉ាវ និងបទពិសោធន៍ដែលបានជួបប្រទះដោយស្មោះត្រង់។ នេះមិនមែនជាពេលធ្វើការរិះគន់ទេ តែជាពេលសម្រាប់ការផ្តល់នូវកង្វល់ និងព័ត៌មានច្បាស់លាស់ និងកសាងនូវសាមគ្គីភាពរឹងមាំក្នុងចំណោមប្រជាពលរដ្ឋ។

សមាជិកម្នាក់របស់ក្រុមស្នូលបានសម្របសម្រួលអង្គប្រជុំដោយសួរសំណួរនានាដូចជា តើមានអ្នកណាម្នាក់ដែលក្រុមហ៊ុនបានប្រាប់ឱ្យចាកចេញពីដីរបស់គេដែរឬទេ? តើទំនាស់ដីខ្លាំងនេះ ប៉ះពាល់ដល់ជីវិតរបស់អ្នកភូមិយ៉ាងណា? តើមានអ្នកណាម្នាក់ត្រូវបានគេគំរាមឬទេ? តើយើងអាចធ្វើការរួមគ្នាដើម្បីដោះស្រាយបញ្ហានេះដោយសន្តិវិធីរបៀបណា? តើយើងគួរនិយាយជាមួយ និងទទួលបានការគាំទ្រពីអ្នកណា? តើមានប្រជាពលរដ្ឋប៉ុន្មាននាក់ដែលយល់ដឹងអំពីច្បាប់ភូមិបាល? តើមានប្រជាពលរដ្ឋប៉ុន្មាននាក់ដែលបានទៅចុះបញ្ជីដីធ្លី និងទទួលបានប័ណ្ណកម្មសិទ្ធិ?

បន្ទាប់ពីបានស្តាប់ព័ត៌មានជាក់ស្តែងរួចមក ក្រុមស្នូលបានសុំឱ្យអ្នកចូលរួមចុះឈ្មោះអ្នកដែលមានលទ្ធភាពដោះស្រាយបញ្ហា។ គ្រប់ៗគ្នាបានឯកភាពគ្នាថា ទោះបីជាមានមនុស្សជាច្រើន មានឥទ្ធិពលដូចជា មិត្តភ័ក្តិ អ្នកជិតខាង គ្រូបង្រៀន ចាស់ទុំ តែអ្នកដែលសំខាន់បំផុតគឺ ក្រុមប្រឹក្សាឃុំ ស្រុក និងអាជ្ញាធរខេត្តទទួលបន្ទុកការចុះបញ្ជីដីធ្លី។ ដូច្នេះក្រុមស្នូលបានសម្រេចជំរុញឱ្យអ្នកភូមិចុះបញ្ជីដីធ្លីរបស់ពួកគេ។ ក្រុមស្នូលក៏បានគិតផងដែរថា ក្រុមប្រឹក្សាឃុំគួរតែជួបជាមួយក្រុមហ៊ុន ដើម្បីពិភាក្សាអំពីសម្បទាន។



**ដីយើង សិទ្ធិយើង។ កុំបេះអាហារពីមាត់ពីកយើង។**

ទោះបីជាពលរដ្ឋសង្ឃឹមថា ក្រុមប្រឹក្សាឃុំនឹងគាំទ្រពួកគេក៏ដោយ តែគ្រប់ៗគ្នាបារម្ភថា រដ្ឋាភិបាលនឹងមិនផ្លាស់ប្តូរនូវសម្បទានឡើយ បើទោះជាមានការគាបសង្កត់ពីសាធារណជនខាងក្រៅក៏ដោយ។ សមាជិកម្នាក់របស់ក្រុមបានស្នើយោបល់ឡើងថា យើងគួរទាក់ទងជាមួយកម្មវិធីផ្សាយបន្តផ្ទាល់របស់វិទ្យុក្នុងតំបន់ និងសារព័ត៌មាននានា នៅទីក្រុងភ្នំពេញ។ អ្នកភូមិបានឯកភាព ហើយនិងស្នើយោបល់ឡើងថា សារដែលអាចបញ្ចុះបញ្ចូលបាន ដើម្បីប្រមូលការគាំទ្រនោះគឺៈ

> នៅពេលដែលប្រជាពលរដ្ឋបានបញ្ចប់ការពិភាក្សាប្តូរយោបល់គ្នាអំពីរឿងរ៉ាវ និងបញ្ហាជួបប្រទះជាក់ស្តែង ហើយជាចាំបាច់យើងត្រូវសុំឱ្យប្រជាពលរដ្ឋនៅក្នុងក្រុមប្រាប់អ្នកនូវពាក្យ ប្រយោគ និងគំនិតដែលគេជឿជាក់ថា អាចបញ្ចុះបញ្ចូល ដើម្បីជំរុញឱ្យអ្នកផ្សេងទៀតជួយគាំទ្រ និងធ្វើការរួមគ្នាដើម្បីដោះស្រាយបញ្ហានេះ។ ដកស្រង់យកប្រយោគមួយឃ្លា ឬ ពីរឃ្លាដែលអ្នកអាចអានបានក្នុងរយៈ៣០វិនាទី ឬតិចជាងនេះ។ នេះហើយជាសារនៃក្រុមរបស់អ្នក។ នៅពេលណាដែលក្រុមស្នូលរបស់អ្នកចូលរួមប្រជុំសហគមន៍និយាយជាមួយមន្ត្រីសាធារណៈ ឬអ្នកជិតខាង ឬនិយាយជាមួយប្រព័ន្ធផ្សព្វផ្សាយ ពួកគេគួរតែព្យាយាមថ្លែងនូវសាររបស់ពួកគេឱ្យបានយ៉ាងហោចណាស់ពីរដងក្នុងអំឡុងពេលសន្ទនានោះ។

## ៤ ស្វែងរកសម្ព័ន្ធមិត្ត



នៅពេលដែលប្រជាពលរដ្ឋស្តាប់ក្រុមស្នូលនិយាយនៅក្នុងសហគមន៍ ពួកគេនឹងចាប់អារម្មណ៍ចូលរួមជាមួយបុព្វហេតុរបស់អ្នក។ ពួកគេអាចមិនធ្វើការច្រើនដូចអ្នកឡើយ តែសូមចងចាំថា យើងត្រូវការមនុស្សចូលរួមឱ្យបានច្រើន តាមតែអាចធ្វើទៅបាន។ ការធ្វើឱ្យមានការផ្លាស់ប្តូរជាការងារដែលលំបាក ហើយវាធ្វើដំណើរលឿន បើយើងសហការជាមួយមនុស្សជាច្រើន។ ចូរស្រមៃថា អ្នកជាគ្រាប់ក្រួសដែលគេបោះទៅក្នុងទឹកស្រះ។ គ្រាប់ក្រួសមួយបង្កើតរលកអង្កាញ់តូចៗបីបួនបាន ហើយក៏រលាយបាត់។ គ្រាប់ក្រួសពីរបីបង្កើតរលកទឹកធំបាន។

សូមស្វែងរកធនធានពីក្រៅសហគមន៍របស់អ្នក។ ប្រសិនបើសហគមន៍របស់អ្នកមានបញ្ហា សហគមន៍ដទៃទៀតក៏នឹងអាចមានបញ្ហាស្រដៀងគ្នានេះដែរ។ ពួកគេប្រហែលជាបានគិតឃើញនូវដំណោះស្រាយថ្មី ឬក៏ពួកគេអាចចង់ចូលរួមតស៊ូជាមួយអ្នក ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរ។



ទោះបីជាការប្រមែប្រមូលសហគមន៍ គួរតែជំរុញនូវស្វ័យរ៉ាប់រងយ៉ាងណាក៏ដោយ ពេលខ្លះយើងត្រូវស្វែងរកជំនួយពីសហគមន៍ខាងក្រៅ ដូចជាអង្គការមិនមែនរដ្ឋាភិបាល រដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ ក្នុងគោលបំណងដើម្បីទទួលបាននូវធនធាន និងធ្វើឱ្យការផ្លាស់ប្តូរកើតឡើង។ មុននឹងទាក់ទងអ្នកណាក៏ដោយ យើងគួរតែច្បាស់លាស់លើអ្វីដែលយើងអាចធ្វើបាន

**ការពារជីវិតរបស់យើង : ស្វែងរកសម្ព័ន្ធមិត្ត**

ក្រុមស្នូលបានសម្រេចថា ពួកគេត្រូវការធ្វើសកម្មភាពមួយដែល អាចទាក់ទាញការយកចិត្តទុកដាក់ពីប្រព័ន្ធផ្សព្វផ្សាយ។ នៅពេលប្រជុំមួយ សមាជិកម្នាក់បានសុំយោបល់ថា សិស្សសាលាអាចមានគំនិតល្អអំពីមូលហេតុ និងរបៀបដែលយើងអាចទាមទារសិទ្ធិកាន់កាប់ដីធ្លីបាន។ ដោយសារគំនិត និងយោបល់នេះ ក្រោយមកពួកគេក៏បានទទួលការអនុញ្ញាតពីនាយកសាលាឱ្យជួបជាមួយសិស្ស ឪពុក និងគ្រូរបស់ពួកគេ។

**សម្គាល់ :** នៅពេលដែលសហគមន៍របស់អ្នកបានចាប់អារម្មណ៍ ចូលរួមជួយដោះស្រាយបញ្ហានឹងមានមនុស្សច្រើនចូលរួម។ ក្នុងការពង្រីកសមាជិកភាពរបស់ក្រុមស្នូលសហគមន៍គួរតែ និងត្រូវបានគេជំរុញឱ្យបោះឆ្នោតឬជ្រើសរើសដោយមតិឯកច្ឆន្ទចំពោះអ្នកណាដែលគេជឿជាក់ថា អាចធ្វើឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានបាន។

### តើអង្គការមិនមែនរដ្ឋាភិបាលអាចជួយអ្នកយ៉ាងដូចម្តេច ?

- ☑ កសាងសមត្ថភាពរបស់ក្រុមស្នូល និង សមាជិកសហគមន៍
- ☑ ជួយផ្សារភ្ជាប់ទំនាក់ទំនងរវាងសហគមន៍ និងមន្ត្រីរដ្ឋាភិបាល និងសមាជិកព្រឹទ្ធសភា និងរដ្ឋសភា
- ☑ ផ្តល់សំឡេងជាប្រចាំចំពោះអ្នកនីតិប្បញ្ញត្តិនូវអ្វីដែលប្រជាពលរដ្ឋបានផ្តល់ឱ្យក្នុងដំណើរការតាក់តែងច្បាប់
- ☑ បង្កើតទំនាក់ទំនងជាមួយសហគមន៍នានាដែលមាននៅគ្រប់ផ្នែកក្នុងប្រទេស
- ☑ ធនធាន : សម្ភារ ជំនួយបច្ចេកទេស និង ថវិកា
- ☑ ធ្វើការស្រាវជ្រាវដែលស្មុគស្មាញ ដូចជាការស្ទង់មតិ ឬការស្រាវជ្រាវផ្នែកច្បាប់
- ☑ បង្កើតការតភ្ជាប់ជាមួយប្រទេសផ្សេងៗ
- ☑ ផ្តល់សេវាផ្នែកច្បាប់

នៅពេលដែលអង្គការមិនមែនរដ្ឋាភិបាលដែលអនុវត្តវិធីសាស្ត្រល្អៗបានជំរុញឱ្យសហគមន៍ទទួលបានបទពិសោធន៍ល្អ មានអង្គការមួយចំនួនជឿជាក់ថា ពួកគេមានតែចំណេះដឹងក្នុងការដោះស្រាយបញ្ហាប៉ុណ្ណោះ។ ពួកគេមិនគួរដឹកនាំការតស៊ូដោយផ្ទាល់ទេ។

ជំនួសមកវិញពួកគេគួរតែជួយសហគមន៍ឱ្យដោះស្រាយបញ្ហារបស់ពួកគេខ្លួនឯងដោយសន្តិវិធី។

# ៥ ធ្វើសកម្មភាពរួមគ្នា

មានសកម្មភាពខុសៗគ្នាជាច្រើន អាស្រ័យលើបញ្ហា។ អ្នកមិនចាំបាច់រៀបចំសកម្មភាពជាច្រើន ដើម្បីរៀបចំព្រឹត្តិការណ៍ធំៗឡើយ។ ជាជំនួយ អ្នកគួរផ្តោតលើពេលវេលា និងធនធានដែលមានកំណត់របស់អ្នក សម្រាប់សកម្មភាពទាំងឡាយណាដែលអាច ទៅដល់អ្នកដែលយើងចង់ឱ្យមានការផ្លាស់ប្តូរឥរិយាបថ។

ខាងក្រោមនេះជាសកម្មភាពមួយចំនួន ដែលអ្នកអាចជ្រើសរើស :

- សម្ភាសន៍ជាមួយកម្មវិធីផ្សាយបន្តផ្ទាល់ ជាមួយវិទ្យុ ឬកាសែតក្នុងតំបន់






- រៀបចំប្រជុំសហគមន៍ ឬការសន្ទនានានា។ ប្រសិនបើបញ្ហារបស់អ្នកត្រូវការការធ្វើច្បាប់ ឬបទបញ្ញា ដើម្បីដោះស្រាយវា គួរជំរុញក្រុមប្រឹក្សាឃុំ ឬ មន្ត្រីរដ្ឋាភិបាលឱ្យចូលរួម ឬក៏យ៉ាងហោចណាស់ ត្រឹមជួយសម្របសម្រួលកិច្ចប្រជុំដែរ។ ជួបពួកគេជាមុន ដើម្បីធានាថាពួកគេយល់ និងឯកភាពជាមួយជំហររបស់អ្នក ។

- រៀបចំឱ្យមានទិវា " និយាយដោយចំហ "។ រៀងរាល់ខែកំណត់យកមួយថ្ងៃសម្រាប់សកម្មជនរបស់អ្នកទាំងអស់ ដែលជាក្រុមស្នូល និងអ្នកស្ម័គ្រចិត្តដើរទៅកាន់ផ្ទះអ្នកថ្មី ដើម្បីនិយាយអំពីបញ្ហាសហគមន៍ ។ ប្រសិនបើអ្នកថ្មីនោះបានចាប់អារម្មណ៍ សុំឱ្យពួកគេស្ម័គ្រចិត្តចូលរួមដើម្បីបុព្វហេតុរបស់អ្នក ឬយ៉ាងហោច ណាស់ ផ្តល់ឈ្មោះមិត្តភ័ក្តិរបស់ពួកគេដើម្បីឱ្យអ្នកបានជួបនិយាយជាមួយ។ ត្រូវគោរពចំពោះមនុស្ស និងយល់ថាពេលវេលារបស់ពួកគេគឺ មានតម្លៃ។ ប្រសិន បើកសិករជាប់រវល់ប្រមូលផល ឬស្ទូងស្រូវ គាត់មិនពេញចិត្តចំពោះការរំខានឡើយ និងមិនស្តាប់សាររបស់អ្នកឡើយ។



- ឧបត្ថម្ភសកម្មភាពសប្បាយសប្បាយសម្រាប់សហគមន៍។ រៀបចំសកម្មភាពមួយក្នុងពេលមានថ្ងៃបុណ្យឈប់សម្រាកដែលមនុស្សភាគច្រើនមានវត្តមាននៅទីនោះ

> បន្ទាប់ពីនិយាយជាមួយសិស្ស ក្រុមស្នូលនៃភូមិស្វាយបានសម្រេចឧបត្ថម្ភការប្រកួតប្រជែងសិល្បៈមួយឡើង។ ចំណងជើងនៃការប្រកួតនោះគឺ "ដីយើង ជីវិតយើង សម្រាប់សហគមន៍យើង " "គ្រប់រូបគំនូររបស់សិស្សត្រូវបានបិទបង្ហាញនៅឯការិយាល័យក្រុមប្រឹក្សាឃុំ និងកន្លែងសាធារណៈផ្សេងៗទៀត។ គ្រប់ៗគ្នានៅក្នុងសហគមន៍ផ្តិតមេដៃរបស់ពួកគេនៅលើក្រដាសមួយសន្លឹក ដែលនៅជិតរូបគំនូរទាំងនោះ ដើម្បីបោះឆ្នោតលើរូបដែលគេពេញចិត្តជាងគេ។ ប្រព័ន្ធផ្សព្វផ្សាយត្រូវបានអញ្ជើញចូលរួមក្នុងពិធីផ្តល់រង្វាន់ចំពោះគំនូរដែលល្អជាងគេ។

- អហិង្សាសកម្ម : ថ្វីបើប្រជាពលរដ្ឋមានអំណាចបដិសេធមិនស្តាប់ ឬបដិសេធមិនស្តាប់អ្នក អ្នកអាចធ្វើសកម្មភាពណាដែលមានកម្លាំងខ្លាំងដើម្បីទាក់ទាញការចាប់អារម្មណ៍ពីពួកគេ។ ការដើរក្បួន និងការប្រមូលផ្តុំទាមទារឱ្យមានការរៀបចំជាមុន តែតាមប្រវត្តិសាស្ត្របានបង្ហាញថា ការតវ៉ាដោយសន្តិវិធី មិនមែនជាអំពើអកម្មឡើយ។ នៅដើមឆ្នាំ ២០០៦ នាយករដ្ឋមន្ត្រីកម្ពុជា ត្រូវបានបង្ខំឱ្យដោះលែងសកម្មជនសិទ្ធិមនុស្សចំនួន ៥នាក់ ដែលត្រូវបានគេចាប់ដាក់ពន្ធនាគារ ក្រោមការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ដោយគ្មានភស្តុតាង ប៉ុន្តែដោយសារតែការធ្វើសកម្មភាពគាបសង្កត់ជាបន្តបន្ទាប់ និងធំធេងពីសាធារណជន។

# សេចក្ដីសន្និដ្ឋាន

ការប្រមែប្រមូលសហគមន៍ដើម្បីប្រឈមមុខ និងដោះស្រាយបញ្ហាពុំមែនជាការងារងាយស្រួយមួយឡើយ។ ជារឿយៗអ្នកសុំប្រជាពលរដ្ឋឱ្យផ្លាស់ប្ដូរឥរិយាបថ ដែលគេជឿថា វាជារឿងធម្មតា ឬក៏ជាកត្តាវប្បធម៌របស់ពួកគេ។ យុទ្ធសាស្ត្រល្អទាមទារការអត់ធ្មត់ តស៊ូ និងការច្នៃប្រឌិត។




## សូមអរគុណជាពិសេសចំពោះ

១. លោកជុំ ណារិន អង្គការសសរទ្រូង

២. លោក ឈិត សំអាត វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា

៣. លោក ឃួន ណារិន អង្គការព្រហ្មវិហារធម៌

៤. លោក ឡាវ លី សមាគមគាំទ្រកសិករជនបទ

៥. លោក មី សុវណ្ណារា អង្គការលីកាដូ ភ្នំពេញ

៦. លោក អ៊ឹង ហ៊្សីឌី គណៈកម្មាធិការប្រព្រឹត្តកម្ម

៧. លោក សរិត អ៊ុត អង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន

៨. លោក ឡេង ប៊ិត អ្នកស្ម័គ្រចិត្តឯករាជ្យ

៩. លោក យ៉ាប់ មេត្តា លោក ឡាំ សុជាតិ អង្គការផេក-កម្ពុជា



# Tactics of advocates around the world

## ADVOCATE

### Formal Statements

Public Speeches
Letters of opposition or support
Declarations by organizations and institutions
Signed public statements
Declarations of indictment and intention
Group or mass petitions

### Communications with a Wider Audience

Slogans, caricatures, and symbols
Banners, posters, and displayed communications
Leaflets, pamphlets, and books
Newspapers and journals
Records, radio, and television
Skywriting and earthwriting

### Group Representations

Deputations
Mock awards
Group lobbying
Picketing
Mock elections

### Symbolic Public Acts

Displays of flags and symbolic colors
Wearing of symbols
Prayer and worship
Delivering symbolic objects
Protest disrobings
Destruction of own property
Symbolic lights
Displays of portraits
Paint as protest
New signs and names
Symbolic sounds
Symbolic reclamations
Rude gestures

### Drama and Music

Humorous skits and pranks
Performances of plays and music
Singing

### Processions

Marches
Parades
Religious processions
Pilgrimages
Motorcades

### Honoring the Dead

Political mourning
Mock funerals
Demonstrative funerals
Homage at burial places

### Public Assemblies

Assemblies of protest or support
Protest meetings
Camouflaged meetings of protest
Teach-ins

### Withdrawal and Renunciation

Walk-outs
Silence
Renouncing honors
Turning one's back

## SOCIAL NON-COOPERATION

### Ostracism of Persons

Social boycott
Selective social boycott

### Noncooperation with Social Events, Customs, and Institutions

Suspension of social and sports activities
Boycott of social affairs
Student strike
Social disobedience
Withdrawal from social institutions

### Withdrawal from the Social System

Stay-at-home
Total personal noncooperation
Protest emigration (hijrat)

## ECONOMIC NON-COOPERATION: Economic

### Actions by Consumers

Consumers' boycott
Non-consumption of boycotted goods
Policy of austerity
Rent withholding
Refusal to rent
National consumers boycott
International consumers boycott

### Action by Workers and Producers

Workmen's boycott
Producers' boycott

## ECONOMIC NON-COOPERATION: The Strike

### Agricultural Strikes

Peasant strike
Farm Workers strike

### Strikes by Special Groups

Refusal of impressed labor
Prisoners strike
Craft strike
Professional strike

### Ordinary Industrial Strikes

Establishment strike
Industry strike
Sympathetic strike

### Restricted Strikes

Detailed strike
Bumper strike
Slowdown strike
Working-to-rule strike
Reporting "sick" (sick-in)
Strike by resignation
Limited strike
Selective strike

### Multi-Industry Strikes

Generalized strike
General strike

### Combination of Strikes and Economic Closures

City Wide Strike
Economic shutdown

## POLITICAL NON-COOPERATION

### Rejection of Authority

Withholding or withdrawal of allegiance
Refusal of public support
Literature and speeches advocating resistance

### Citizens' Noncooperation with Government

Boycott of legislative bodies
Boycott of elections
Boycott of government employment and positions
Boycott of government departments, agencies, and other bodies
Withdrawal from government educational institutions
Boycott of government-supported organizations
Refusal of assistance to enforcement agents
Removal of own signs and placemarks
Refusal to dissolve existing institutions

### Citizens' Alternatives to Obedience

Reluctant and slow compliance
Non-obedience in absence of direct supervision
Popular non-obedience
Disguised disobedience
Refusal of an assemblage or meeting to disperse
Sitdown
Noncooperation with conscription and deportation
Hiding, escape, and false identities
Civil disobedience of "illegitimate" laws

### International Governmental Action

Changes in diplomatic and other representations
Delay and cancellation of diplomatic events
Withholding of diplomatic recognition
Severance of diplomatic relations
Withdrawal from international organizations
Refusal of membership in international bodies
Expulsion from international organizations

## NONVIOLENT INTERVENTION

### Psychological Intervention

Self-exposure to the elements
The Fast
Reverse trial
Nonviolent harassment

### Physical Intervention

Sit-in
Stand-in
Ride-in
Wade-in
Pray-in
Nonviolent obstruction

### Social Intervention

Establishing new social patterns
Speak-in
Theater
Alternative social institutions
Alternative communication system

### Economic Intervention

Reverse strike
Stay-in strike
Defiance of blockades
Preclusive purchasing
Dumping
Alternative markets
Alternative transportation systems
Alternative economic institutions

### Political Intervention

Overloading of administrative systems
Disclosing identities of secret agents
Seeking imprisonment
Civil disobedience of "neutral" laws
Dual sovereignty and parallel government

*Adapted from Gene Sharp, The Politics of Nonviolent Action, Vol. 2: The Methods of Nonviolent Action (Boston: Porter Sargent Publishers, 1973).*

# សន្ទានុក្រម

### សម្ព័ន្ធភាព

ជាការប្រមូលផ្តុំរវាងក្រុមមនុស្ស អង្គការ ឬ ប្រជាជាតិ ក្នុងរយៈពេលខ្លី ដើម្បីសម្រេចគោលបំណងជាក់លាក់ណាមួយ ដែលយើងផ្តោតទៅរក។

### អាជ្ញាធរ

អំណាចដើម្បីបង្គាប់បញ្ជាមនុស្ស ឬ សិទ្ធិដើម្បីធ្វើអ្វីមួយ។

### ការព្រមព្រៀងមតិ / កុងសង់ស៊ីស

មតិ ឬ ការសម្រេចធ្វើឡើងដោយមនុស្សមួយក្រុម។

### ការពិគ្រោះយោបល់

អំពើនៃការពិភាក្សាលើអ្វីមួយជាមួយអ្នកណាម្នាក់មុននឹងធ្វើសេចក្តីសម្រេច។

### ផ្ទេរភារកិច្ច

ប្រគល់ ឬ ផ្ទេរ អំណាច សិទ្ធិ ឬការទទួលខុសត្រូវទៅបុគ្គល ឬក្រុមមួយទៀត។

### បណ្តាញ

ជាក្រុមមនុស្ស ឬអង្គការមួយក្រុមដែលមានចំណាប់អារម្មណ៍ ឬ ការព្រួយបារម្ភប្រហាក់ប្រហែលគ្នា ដើម្បីផ្លាស់ប្តូរព័ត៌មាន ឬយោបល់។

### ប្រមែប្រមូល

ធ្វើការរួមគ្នាក្នុងគោលបំណង ដើម្បីសម្រេចគោលបំណងជាក់លាក់រៀបចំក្រុមមនុស្ស ដើម្បីធ្វើអ្វីមួយ។

### កាតព្វកិច្ច

អ្វីដែលអ្នកត្រូវតែធ្វើ ព្រោះដោយសារជាភារកិច្ច ឬច្បាប់តម្រូវ។

# ឯកសារយោង

សម្រាប់ព័ត៌មានបន្ថែម លើប្រធានបទនេះ សូមមើល :

**ការតស៊ូមតិដើម្បីការចាក់ថ្នាំបង្ការ**
សម្ព័ន្ធសកលដើម្បីថ្នាំបង្ការ និង ការចាក់ថ្នាំបង្ការ (២០០១)

**កញ្ចប់បណ្តុះបណ្តាលប្រព័ន្ធផ្សព្វផ្សាយចម្រុះ-យូណេស្កូ**/APC
ការស្រាវជ្រាវដើម្បីមូលដ្ឋានរួម
*http://www.itrainonline.org/*

**ACT UP: ការបណ្តុះបណ្តាលអំពីការមិនស្តាប់បង្គាប់ជនស៊ីវិល**
http://www.actupny.org

**ឧបករណ៍នៃការគិត :**
*http://www.mindtools.com*

**ការប្រតិបត្តិល្អលើការចូលរួម**
ការិយាល័យផ្នែកស្ម័គ្រចិត្ត និង សហគមន៍
*http://www.goodpracticeparticipate.govt.nz*

**ដំណោះស្រាយអភិវឌ្ឍន៍ផលិតផលថ្មី**
*http://www.npd-solutions.com*

**ឧបករណ៍តស៊ូមតិ និង ការណែនាំ :**
**ការលើកម្ពស់ការផ្លាស់ប្តូរគោលនយោបាយ**
Sofia Sprechman nig Emily Pelton, CARE (2001)
*http://www.careusa.org/getinvolved/advocacy/tools.asp*

**ឯកសារសិទ្ធិមនុស្សអន្តរជាតិ**
*http://www.cambodia.ohchr.org*

# ឯកសារបន្ថែម

សម្រាប់ព័ត៌មានបន្ថែម លើប្រធានបទនេះ សូមមើល :

- សៀវភៅក្រុមភោកម្រងអត្ថបទសម្រាប់ជំនាញតស៊ូមតិ រៀបចំដោយអង្គការផេក-កម្ពុជា :
  ១. ការគ្រប់គ្រងយុទ្ធនាការតស៊ូមតិ
  ២. ការកសាងទំនាក់ទំនងជាមួយរដ្ឋាភិបាល
  ៣. ការធ្វើការជាមួយប្រព័ន្ធផ្សព្វផ្សាយ
  ៤. ការកសាង និងថែរក្សាក្រុមចម្រុះ
  ៥. កាតស៊ូមតិតាមរយៈសេវាកម្មច្បាប់

- កញ្ចប់ឧបករណ៍តស៊ូមតិ Graham Gordon : ការយល់ដឹងលើការតស៊ូមតិ Tearfund ភាគ ១ និង ២ ឆ្នាំ ២០០២
- សៀវភៅណែនាំអំពីការតស៊ូមតិថ្នាក់មូលដ្ឋាន អង្គការផេក-កម្ពុជា ឆ្នាំ ២០០៦
- សៀវភៅណែនាំសម្រាប់ការបណ្តុះបណ្តាល InWent និងអង្គការលូថេរ៉ានបំរើពិភពលោក: ជំនាញសម្របសម្រួលសម្រាប់ ការពង្រឹងអំណាចប្រជាពលរដ្ឋ ឆ្នាំ ២០០៤

**ឧបត្ថម្ភដោយ ៖**

British Embassy
Phnom Penh

**ប្រសិនបើចង់បានសៀវភៅនេះបន្ថែម សូមទាក់ទង ៖**

BUILDING
CAPACITY
WORLDWIDE
Pact Cambodia


មជ្ឈមណ្ឌលភ្នំពេញ ជាន់ទី៣
កែងផ្លូវព្រះសីហនុ (២៧៤) និង មហាវិថីព្រះសុធារស
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ១៤៩ ប្រៃសណីយ៍ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ (៨៥៥-២៣) ២១៧ ៨៥៥
ទូរសារ (៨៥៥-២៣) ២១៧ ៨៥៦

**www.pactcambodia.org**